**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

លេខ៖ ៨៧ ប្រក/បុ

# ប្រកាស
## ស្តីពី
## ការបង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-តាមការចាំបាច់របស់ក្រសួង

## <u>សម្រេច</u>

**ប្រការ ១** ៖ ត្រូវបានបង្កើត សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ថ្នាក់ស្មើការិយាល័យចំណុះមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**ប្រការ ២** ៖ សាលាបណ្តុះបណ្តាលវិជ្ជាជីវៈដឹកនាំដោយនាយក ០១រូប និង នាយករងមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**ប្រការ ៣** ៖ សាលាបណ្តុះបណ្តាលវិជ្ជាជីវៈមានភារកិច្ចរៀបចំបើកវគ្គបណ្តុះបណ្តាលអំពីមុខជំនាញរៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រ ។

**ប្រការ ៤** ៖ នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋាន ប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៩

**ទេសរដ្ឋមន្ត្រី**

**អ៊ឹម ឈុនលឹម**

**<u>កន្លែងទទួល</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័ន

-ខុទ្ទកាល័យ លោកជំទាវឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន

-គ្រប់សាលារាជធានី ខេត្ត

-គ្រប់មន្ទីរដ.ន.ស.ស រាជធានី ខេត្ត

-ដូចប្រការ ៤ (ដើម្បីអនុវត្ត)

-ឯកសារ-កាលប្បវត្តិ